# របាយការណ៍ប្រចាំត្រីមាសទី៣ ឆ្នាំ២០២៤

០១ កក្កដា - ៣០ កញ្ញា ២០២៤

## អ អិម អេ (ខេមបូឌា) ម.ក

## R M A (CAMBODIA) PLC.

ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក
ទីស្នាក់ការចុះបញ្ជីផ្ទះលេខ ២៧ ផ្លូវលេខ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទទំនាក់ទំនង: +៨៥៥ (0) ២៣-៨៨៨-000, ទូរស័ព្ទចល័ត: +៨៥៥ (0) ២៣-៤២៦-៧៥២
www.cambodia.rmagroup.net

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាពាន់រៀល) | ត្រីមាសទី៣ ឆ្នាំ២០២៤ | ២០២៣ | ២០២២ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ៨៥៨.៥៨៦.៩៥៨ | ១.០៩៣.៥១១.៧១០ | ៨៨៩.២៩៥.២៣២ |
| បំណុលសរុប | ៣៣៩.០៨៨.៧៨៤ | ៥៨៦.៦០៩.៧៤៦ | ៤៥១.៣៩២.៤៣៣ |
| មូលធនក្រុមហ៊ុនសរុប | ៥១៩.៤៩៨.១៧៤ | ៥០៦.៩០១.៩៦៤ | ៤៣៧.៩០២.៧៩៩ |

| ប្រាក់ចំណេញ/(ខាត) (គិតជាពាន់រៀល) | ត្រីមាសទី៣ ឆ្នាំ២០២៤ | ត្រីមាសទី៣ ឆ្នាំ២០២៣ | ត្រីមាសទី៣ ឆ្នាំ២០២២ |
|---|---|---|---|
| ចំណូលសរុប | ៣៦១.៣១៣.៩១១ | ៣៦៦.៦៥៧.៧១០ | ៧៨៥.៦៩៣.៨៩១ |
| ប្រាក់ចំណេញដុល | ៥២.៧៤៩.៧៧៤ | ៥៨.៦៤៤.៨៧៧ | ១៥០.៥៦៨.៣៧៥ |
| ប្រាក់ចំណេញពីកិច្ចប្រតិបត្តិការ | ២១.៦០៨.៣០៦ | ២៤.៧០៧.៤១៨ | ១២៥.០៦៣.៣១៦ |
| បន្ទុកហិរញ្ញប្បទាន | ៥.៦៥៤.៩៩៧ | ៨.៧៥២.០៧២ | ៣.៤៧៣.៨៣៤ |
| ប្រាក់ចំណេញ/(ខាត)មុនបង់ពន្ធ | ១៥.៩៥៣.៨០៩ | ១៥.៩៥៥.៣៤៦ | ១២១.៥៨៩.៤៨២ |
| ប្រាក់ចំណេញ (ខាត) ក្រោយបង់ពន្ធ | ១២.១៥៥.២៦៨ | ១៣.២៤៣.៥១៩ | ៩៨.៤៣៦.៩៧៩ |
| លទ្ធផលចំណេញលម្អិតក្នុងគ្រា | ៥.៩៧៤.០៨៩ | ១០.៥៩៧.៣៧៦ | ១០១.០៩០.៦១៨ |

| អនុបាតហិរញ្ញវត្ថុ | ត្រីមាសទី៣ ឆ្នាំ២០២៤ | ២០២៣ | ២០២២ |
|---|---|---|---|
| អនុបាតសាធនភាព | ០,៧ | ១,២ | ១,០ |
| អនុបាតចរន្ត (Current Ratio) | ៤,៩ | ២,៥ | ២,០ |
| អនុបាតចរន្តលឿន (Quick Ratio) | ២,៧ | ០,៦ | ០,៧ |

| អនុបាតចំណេញភាព | ត្រីមាសទី ៣ ឆ្នាំ២០២៤ | ត្រីមាសទី ៣ ឆ្នាំ២០២៣ | ត្រីមាសទី ៣ ឆ្នាំ២០២២ |
|---|---|---|---|
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ០,៦% | ១,១% | ១៤,៦% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ១,២% | ២,២% | ២៩,៥% |
| គម្លាតចំណេញដុល (Gross Profit Margin) | ១៤,៦% | ១៦,០% | ១៩,២% |
| គម្លាតចំណេញ (Profit Margin) | ១,៧% | ២,៩% | ១២,៩% |
| អនុបាតលទ្ធភាពបង់ការប្រាក់ | ៣,៨ | ២,៨ | ៣៦,០ |

## ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប










ប្រាក់ចំណូល និង ចំណូលសុទ្ធ ( គិតជាពាន់រៀល )
2,500,000,000
2,000,000,000
1,500,000,000
1,000,000,000
500,000,000
-
12.0%
10.0%
8.0%
6.0%
4.0%
2.0%
0.0%
១១,២%
២.២០៣.២៥៣.៤៥៣
១.៨០០.៣៦២.០៩៤
៦,១%
១.២៣៥.០០៣.៤៧០
៤,១%
២០២២
២០២៣
មករា ដល់ កញ្ញា, ២០២៤
ប្រាក់ចំណូល
ចំណូលសុទ្ធ%

# សមាជិកក្រុមប្រឹក្សាភិបាល



លោក Christian Wiedmann | លោក ខន សាំខ | លោក Kevin Whitcraft | លោក Tom Whitcraft | លោក Ith Vichit

លោក Kevin Whitcraft

**ប្រធានក្រុមប្រឹក្សាភិបាល**

លោក ខន សាំខ

**អភិបាលប្រតិបត្តិ**

លោក Tom Whitcraft

**អភិបាលមិនប្រតិបត្តិ**

លោក Christian Wiedmann

**អភិបាលមិនប្រតិបត្តិ**

លោក Ith Vichit

**អភិបាលឯករាជ្យ**

## សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព

ក្នុងរបាយការណ៍ប្រចាំត្រីមាសមុនៗ ខ្ញុំបាទបានជម្រាបជូនអំពីរបាយការណ៍សង្ខេបស្តីពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក (តទៅនេះហៅកាត់ថា "ក្រុមហ៊ុន RMAC") ស្របទៅតាមលក្ខខណ្ឌតម្រូវរបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក)។

ក្នុងរបាយការណ៍ត្រីមាសកន្លងមក ខ្ញុំបានចែករំលែកសូចនាករម៉ាក្រូសេដ្ឋកិច្ច ដែលថ្មីៗនេះមិនបានផ្លាស់ប្តូរអ្វីគួរឱ្យកត់សម្គាល់នោះទេ ដោយហេតុថាធនាគារពិភពលោក និងធនាគារអភិវឌ្ឍអាស៊ីនៅតែព្យាករណ៍ថាកំណើនផលិតផលក្នុងស្រុកសរុប (GDP) នឹងកើនឡើងដល់ចំនួន ៥,៨%ក្នុងឆ្នាំ២០២៤។ វិស័យសំខាន់ៗមួយចំនួនដូចជា វិស័យសម្លៀកបំពាក់ ស្បែកជើង និងការចរាចរណ៍ទំនិញ (GFT) ការនាំចេញ បានបង្ហាញពីកំណើនដ៏រឹងមាំចំនួន +១៧% សម្រាប់ត្រីមាសទីមួយនៃឆ្នាំនេះ។ ការមកដល់នូវភ្ញៀវទេសចរណ៍បានកើនឡើងចំនួន +២២% នៅក្នុងត្រីមាសទីមួយនៃឆ្នាំនេះ។ ហើយវិស័យកសិកម្មត្រូវបានគេប៉ាន់ស្មានថាមានការលូតលាស់ក្នុងភាគរយខ្ទង់រាយប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ វិស័យសំណង់នៅតែមានការធ្លាក់ចុះជាមួយនឹងការលក្ខខណ្ឌទីផ្សារអចលនទ្រព្យ ហើយវិស័យធនាគារកំពុងស្ថិតក្រោមសម្ពាធដែលបង្ហាញតាមរយៈចំនួនកម្ចីមានបញ្ហាក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ។ សរុបមក កម្ពុជាបច្ចុប្បន្នកំពុងជួបប្រទះបញ្ហាប្រឈមមួយចំនួនផ្នែកសេដ្ឋកិច្ច។

ចក្ខុវិស័យនៃទីផ្សាររថយន្ត ទីផ្សាររួមក្នុងរយៈ៩ខែដំបូងនៃឆ្នាំនេះ នៅតែមានការធ្លាក់ចុះ-៥% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំកន្លងទៅ ខណៈដែលទីផ្សាររថយន្តថ្មីមានការកើនឡើងចំនួន +៤% ។ មានតែក្នុងរយៈពេល ៤ ខែចុងក្រោយនេះទេ ដែលយើងបានឃើញការលក់រថយន្តថ្មីកាន់តែខ្លាំង (មានចំនួន +៤២%) បើប្រៀបធៀបទៅនឹងខែដូចគ្នាកាលពីឆ្នាំមុន។ នេះគឺជាការប្រសើរឡើងដ៏គួរឱ្យកត់សម្គាល់។

នៅក្នុងត្រីមាសនេះ ប្រាក់ចំណូលរបស់ក្រុមហ៊ុន RMAC បានធ្លាក់ចុះ ១,៥% បើប្រៀបធៀបទៅនឹងត្រីមាសដូចគ្នាក្នុងឆ្នាំ២០២៣។ ក្រឡេកមើលប្រតិបត្តិការនៃការលក់ពីដើមឆ្នាំ២០២៤ ដល់បច្ចុប្បន្ន ក្រុមហ៊ុន RMAC បានកត់ត្រាការលក់សរុបមានការធ្លាក់ចុះចំនួន -១៦,៨% បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០២៣។ ប្រាក់ចំណេញសុទ្ធប្រចាំត្រីមាសទាបជាង -៨% បើធៀបនឹងត្រីមាសកាលពីឆ្នាំមុន។ តារាងតុល្យការនៅតែមានភាពរឹងមាំជាមួយនឹងសមតុល្យសាច់ប្រាក់ ដែលតំណាងឱ្យការកើនឡើងនៃសាច់ប្រាក់ចំនួន ៤៩ ពាន់លានរៀល បើធៀបនឹងខែធ្នូ ឆ្នាំ២០២៣។

ក្រុមការងារ RMAC របស់យើងមានភាពសកម្មយ៉ាងខ្លាំងក្នុងអំឡុងត្រីមាសនេះ ជាមួយនឹងការសម្ពោធជាផ្លូវការនៃរថយន្តអគ្គិសនីដំបូងរបស់យើងជាមួយនឹងម៉ូដែល Deepal ចំនួនពីរម៉ូដែលគឺ L07 និង S07 ។ នេះជាការកត់ត្រាព្រឹត្តិការណ៍សំខាន់មួយសម្រាប់ ក្រុមហ៊ុន RMAC ឆ្ពោះទៅរកការច្នៃប្រឌិតបច្ចេកវិទ្យា និងការលើកកម្ពស់ការដឹកជញ្ជូនប្រកបដោយនិរន្តរភាព។ ក្រុមហ៊ុន RMAC ក៏មានមោទនភាពផងដែរដែលបានបើកដំណើរការចែកចាយផ្តាច់មុខនូវរថយន្តម៉ាកពីរដ៏ល្បីល្បាញរបស់អាមេរិកគឺ Jeep និង RAM នៅក្នុងទីតាំងអគារបង្ហាញរថយន្តដ៏ទំនើបបំផុតរបស់យើង។ ជាចុងក្រោយ ផ្នែកគ្រឿងចក្រកសិកម្ម និងបរិក្ខារធុនធ្ងន់របស់យើង បានពង្រីងបណ្តាញតាំងបង្ហាញ ដោយការបន្ថែមអគារតាំងបង្ហាញសម្រាប់គ្រឿងចក្រម៉ាកថ្មីៗរបស់យើង នៅលើផ្លូវជាតិលេខ៦។

ខាងផ្នែកទំនួលខុសត្រូវសង្គមសាជីវកម្ម ក្រុមហ៊ុន RMAC មានសេចក្តីសោមនស្សរីករាយដែលបានបរិច្ចាគនូវថវិកាមួយចំនួនដល់មន្ទីពេទ្យគន្ធបុប្ផា ព្រមទាំងបានចូលរួមដាំដើមឈើចំនួនច្រើនជាង១.៣០០ដើមក្នុងខេត្តសៀមរាប។

ក្នុងនាមខ្ញុំបាទតំណាងឱ្យក្រុមប្រឹក្សាភិបាលទាំងអស់ សូមថ្លែងអំណរគុណចំពោះអតិថិជនទាំងអស់នៅក្នុងប្រទេសកម្ពុជា ដែលតែងតែមានភក្ដីភាព និងមានការចូលចិត្ត និងតែងតែគាំទ្រដល់ក្រុមហ៊ុនយើងខ្ញុំកន្លងមក។ យើងខ្ញុំសូមជូនពរដល់ប្រជាជនកម្ពុជាទាំងអស់ សូមមានសុខសុវត្ថិភាព និងសុខភាពល្អជានិច្ចនិរន្តន៍។

លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល
កាលបរិច្ឆេទ៖ ២៩ វិច្ឆិកា ២០២៤

## មាតិកា

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ 3
ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប ........ 4
សមាជិកក្រុមប្រឹក្សាភិបាល ........ 6
សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល........ 7
ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ ........ 10
កព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ . ........ 10
ខសកម្មភាពអាជីវកម្ម ........ 10
គព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស . ........ 11
ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ 14
ក. លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក........ 14
ខ. រចនាសម្ព័ន្ធប្រាក់ចំណូល........ 15
ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ ........ 16
ផ្នែកទី៤ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង . ........ 17
កទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ 17
ខកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ . ........ 18
គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល........ 18
ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ........ 18
ង. ផលប៉ះពាល់នៃអតិផរណា........ 18
ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ........ 18
ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ........ 18
ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ........ 19

## ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

### ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាខ្មែរ | អ អិម អេ (ខេមបូឌា) ម.ក |
|---|---|
| ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាឡាតាំង | RMA (CAMBODIA) PLC |
| លេខកូដស្តង់ដារ | KH2000121A44 |
| អាសយដ្ឋាន | ផ្ទះលេខ ២៧ E1 ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០) ២៣ ៨៨៣ ៩៨៨ / ១២ ៨៦៧ ៦៩៧ |
| លេខទូរសារ | +៨៥៥ (០) ២៣ ៩២៦ ៧៥២ |
| គេហទំព័រ | www.cambodia.rmagroup.net |
| អ៊ីម៉ែល | saing.ngorn@rmagroup.net |
| លេខចុះបញ្ជីក្រុមហ៊ុន | ០០០០១១២១ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០២ |
| លេខចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ០៦៨/២០ គ.ម.ក សសរ SECC ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ |
| ឈ្មោះអ្នកតំណាងរបស់ក្រុមហ៊ុនបោះផ្សាយ | លោក ងន សាំង |
| លេខាធិការក្រុមហ៊ុន | លោក មាស សុវណ្ណ (អ៊ីមែល៖ sovan.meas@rmagroup.net) |

### ខ. សកម្មភាពអាជីវកម្ម

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត កសិកម្ម និងគ្រឿងបន្លាស់ធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមានដូចជា Ford, Changan, Land Rover, សេវាកម្មក្រោយការលក់ Jeep & RAM, សេវាកម្មក្រោយការលក់ Mercedes-Benz, TCM, JCB, FUSO, John Deere, MS Pallet, Megger & Sebar, GenieGrips, Hako, PowerBoss, AJAX, Piaggio, Haulotte, និងគ្រឿងបន្លាស់រថយន្ត (ថ្នាំលាបរថយន្ត និង អាគុយ)។

ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និង ផ្តល់ដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងសេវាថែទាំក្រោយការលក់។

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។

## គ. ព្រឹត្តិការណ៍សំខាន់ៗក្នុងរយៈពេលនៃរបាយការណ៍ត្រីមាស

ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសត្រូវបានកំណត់ដូចខាងក្រោម៖

### ខែ កក្កដា ឆ្នាំ២០២៤

**ការបរិច្ចាគក្នុងព្រឹត្តិការណ៍រត់ដើម្បីជីវិត**

កម្មវិធីសប្បុរសធម៌មួយត្រូវបានរៀបចំឡើងក្រោមការដឹកនាំរបស់លោក ងន សាំង ជានាយកប្រតិបត្តិ ដែលមានការចូលរួមពីបុគ្គលិករបស់ ក្រុមហ៊ុន RMAC។ ថវិកាដែលរៃអង្គាសបាន ត្រូវបានប្រគល់ជូនមន្ទីរពេទ្យគន្ធបុប្ផាទី៣ (មន្ទីរពេទ្យជ័យវរ្ម័នទី៧) ខេត្តសៀមរាប។




### ខែ កក្កដា ឆ្នាំ២០២៤

**CAMBODIA VIN សម្រាប់រថយន្ត FORD**

លេខ VIN លើរថយន្តសម្រាប់គម្រោង IKD-1 បង្ហាញថារថយន្តនេះត្រូវបានដំឡើងនៅក្នុងប្រទេសកម្ពុជា។ ប្រសិនបើរថយន្តត្រូវបាននាំចេញ ប្រទេសដែលនាំចូលអាចទទួលស្គាល់ប្រភពដើមនៃរថយន្ត ថាជារបស់(កម្ពុជា) ដោយស្កេនលេខ VIN ។




ក្រុមហ៊ុន អ អិម អេ ខេមបូឌា មានមោទនភាពក្នុងការក្លាយជា ក្រុមហ៊ុនដំឡើងរថយន្តដំបូងគេក្នុងប្រទេសកម្ពុជា ដោយសម្រេចបានការទទួលស្គាល់ លេខVIN ទូទាំងពិភពលោក ខណៈដែលរថយន្តត្រូវបានផលិតនៅក្នុងប្រទេសកម្ពុជា។

### ខែ កក្កដា ឆ្នាំ២០២៤

**ការឧបត្ថម្ភរបស់ DAVIS CUP**




នៅថ្ងៃទី០៣ ខែកក្កដា ជាសន្និសីទសារព័ត៌មានសម្រាប់ព្រឹត្តិការណ៍ Davis Cup Asia Oceania International Tennis Group IV ឆ្នាំ២០២៤ ។ ក្រុមហ៊ុន RMAC គឺជាអ្នកឧបត្ថម្ភធំមួយនៃព្រឹត្តិការណ៍នេះ។

## ខែ សីហា ឆ្នាំ២០២៤

### ការសម្ពោធជាផ្លូវការ នៃរថយន្តម៉ាក CHANGAN DEEPAL EV

ថ្ងៃទី២៣ ខែសីហា ក្រុមហ៊ុន RMAC បានណែនាំរថយន្តអគ្គិសនីចំនួនពីរម៉ូដែល Changan Deepal L07 និង S07 ដោយមោទនភាព។ ម៉ូដែលទាំងពីរនេះគឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយនៅក្នុងដំណើររបស់ប្រទេសកម្ពុជាឆ្ពោះទៅរកការច្នៃប្រឌិតបច្ចេកវិទ្យា និងការដឹកជញ្ជូនប្រកបដោយនិរន្តរភាព




## ខែ សីហា ឆ្នាំ២០២៤

### បើកដំណើរការសេវាកម្មក្រោយការលក់ផ្តាច់មុខជាមួយ JEEP និង RAM

ថ្ងៃទី១២ ខែសីហា ផ្នែក RMAC Stellantis បានប្រកាសទទួលថា បានធានាសិទ្ធិផ្តាច់មុខក្នុងការផ្តល់សេវាថែទាំលើរថយន្ត Jeep និង RAM brnads នៅក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុន RMAC ប្តេជ្ញាក្នុងការផ្តល់សេវាកម្មលំដាប់កំពូល តាមរយៈគ្រឿងបរិក្ខារទំនើបៗ និងអ្នកបច្ចេកទេសដែលមាន ការបណ្តុះបណ្តាលខ្ពស់។




## ខែ សីហា ឆ្នាំ២០២៤

### សម្ពោធរថយន្ត FUSO FIRST MOVING DAIRY QUENING នៅកម្ពុជា

កាលពីថ្ងៃទី០៩ ខែសីហា FUSO Canter FE71 ត្រូវបានដាក់លក់ជាផ្លូវការក្នុងប្រទេសកម្ពុជា ជារថយន្ត Dairy Queen Icream ដំបូងបង្អស់ក្នុងប្រទេស។ វាបង្ហាញពីសមត្ថភាពពិសេសរបស់រថយន្ត FUSO ដែលអាចបទបែនបានតាមបំណង។



## ខែ កញ្ញា ឆ្នាំ២០២៤

### 2024 HR ASIA AWARDS

នៅថ្ងៃទី២៧ ខែកញ្ញា ក្រុមហ៊ុន RMAC បានទទួលពានរង្វាន់ធំ មានកិត្យានុភាពចំនួនពីរសម្រាប់ "ក្រុមហ៊ុន ល្អបំផុតដើម្បីធ្វើការនៅអាស៊ី" និង "ក្រុមហ៊ុនដែលយកចិត្តទុកដាក់បំផុត" ។ នេះឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំក្រុមហ៊ុនរបស់យើង ក្នុងការលើកកម្ពស់វប្បធម៌កន្លែងធ្វើការជាវិជ្ជមាន និងការប្តេជ្ញាចិត្តយ៉ាងជ្រាលជ្រៅ ចំពោះសុខុមាលភាពរបស់បុគ្គលិកនៅក្នុងប្រទេសកម្ពុជា។




## ខែ កញ្ញា ឆ្នាំ២០២៤

### ការដាំដើមឈើនៅខេត្តសៀមរាប

នៅថ្ងៃទី២១ ខែកញ្ញា ក្រុមហ៊ុន RMAC និងបុគ្គលិករបស់ក្រុមហ៊ុន បានដាំដើមឈើចំនួន ១,៣៥០ដើម នៅតាមបណ្តោយផ្លូវជាតិលេខ៦ ក្នុងខេត្តសៀមរាប។ ព្រឹត្តិការណ៍នេះ ប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម យន់ លីនណេ អភិបាលរងខេត្តសៀមរាប និងលោក សាំង ងន ជានាយកប្រតិបត្តិ នៃក្រុមហ៊ុន RMAC។



## ខែ កញ្ញា ឆ្នាំ២០២៤

### ក្រុមហ៊ុន RMAC ជាដៃគូសហការជាមួយក្រសួងការងារ

កាលពីថ្ងៃទី០៩ ខែកញ្ញា ក្រុមហ៊ុន RMAC បានចុះហត្ថលេខា លើអនុស្សរណៈ នៃការយោគយល់គ្នាជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) ស្តីពី "កិច្ចសហប្រតិបត្តិការលើវិស័យការងារ សន្តិសុខសង្គម និងការបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈកម្មវិធីហ្វឹកហ្វឺនកូនជាង ការបណ្តុះបណ្តាលតាមបច្ចេកវិទ្យាចុងក្រោយ និងសេវាការងារសាធារណៈ" ក្រោមអធិបតីភាព ឯកឧត្តម ហេង សួរ។ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។



## ខែ កញ្ញា ឆ្នាំ២០២៤

### ការបើកសម្ពោធបន្ទប់តាំងបង្ហាញថ្មី

កាលពីថ្ងៃទី០៩ ខែកញ្ញា ក្រុមហ៊ុន RMAC បានបើកសម្ពោធជាផ្លូវការនូវបន្ទប់តាំងបង្ហាញថ្មី សម្រាប់ផ្នែករថយន្តកសិកម្ម (John Deere) និងបរិក្ខារធុនធ្ងន់ (JCB) នៅលើផ្លូវជាតិលេខ ៦។ ព្រឹត្តិការណ៍នេះប្រព្រឹត្តទៅក្រោមអធិបតីភាពលោកស្រី Yajun Bian នាយកទីផ្សារ និងលក់ John Deere និង លោក ងន សាំង ជានាយកប្រតិបត្តិនៃក្រុមហ៊ុន RMAC។



## ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក. លទ្ធផលប្រតិបត្តិការធុរកិច្ច និង ព័ត៌មានធុរកិច្ចតាមផ្នែក

សរុបទីផ្សាររថយន្តថ្មីនៅកម្ពុជាចាប់ពីថ្ងៃដំបូងនៃឆ្នាំប្រតិទិនរហូតចុងខែកញ្ញា ឆ្នាំ២០២៤ ត្រូវបានប៉ាន់ស្មានថាបានកើនឡើង +៤% ធៀបនឹងឆ្នាំមុន ដែលមានចំនួនតិចជាង ១៩.០០០ គ្រឿង។

ក្នុងកំឡុងត្រីមាសទី៣ ការអនុវត្តរបស់ ក្រុមហ៊ុន RMAC នៅក្នុងផ្នែកសំខាន់ៗគឺ៖

**<u>ផ្សាររបស់រថយន្តម៉ាក Ford៖</u>**

រថយន្តម៉ាក Ford នៅតែរក្សាចំណាត់ថ្នាក់លេខមួយនៃរថយន្តដែលលក់ដាច់បំផុតនៅលើទីផ្សារនៃប្រទេសកម្ពុជា ក្នុងចំណោមទីផ្សាររថយន្តដែលមិនប្រណិត ជាមួយនឹងរថយន្តម៉ាក Ford Ranger ត្រូវបានជាប់ចំណាត់ថ្នាក់លេខមួយ ដែលលក់ដាច់បំផុតនៅលើទីផ្សារក្នុងប្រទេសកម្ពុជា។ យើងពិតជាមានមោទនភាពដែលរថយន្តដែលលក់បានភាគច្រើនត្រូវបានផលិតក្នុងប្រទេសកម្ពុជា។

**<u>គ្រឿងចក្រម៉ាក John Deere៖</u>** ដោយយោងតាមរបាយការណ៍ផ្ទៃក្នុងរបស់ក្រុមហ៊ុន គ្រឿងចក្រម៉ាក John Deere នៅជាអ្នកនាំមុខទី២ នៅក្នុងទីផ្សារត្រាក់ទ័រក្នុងប្រទេសកម្ពុជា និងរក្សាតំណែងជាអ្នកនាំមុខលើត្រាក់ទ័រធុនធំ និងម៉ាស៊ីនប្រមូលផលនៅកម្ពុជា ហើយបានដណ្តើមយកចំណាត់ថ្នាក់ទីផ្សារវិញក្នុងកំឡុងឆ្នាំ ២០២៣។

**<u>លទ្ធផលហិរញ្ញវត្ថុ៖</u>**

ដោយសារការស្ទះដើបឡើងវិញនៃទីផ្សាររបស់រថយន្ត ព្រមទាំងទិដ្ឋភាពវិជ្ជមាននៃវិស័យកសិកម្ម ក្រុមហ៊ុន RMAC ទទួលបានប្រាក់ចំណូលចំនួន ៣៦១,៣ ប៊ីលានរៀល ដែលមានការធ្លាក់ចុះ -១,៥% បើប្រៀបធៀបនឹងឆ្នាំមុន។ សម្រាប់ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ ប្រាក់ចំណេញក្រោយបង់ពន្ធមានចំនួន ១២,១ ប៊ីលានរៀល ធ្លាក់ចុះ -៨% ធៀបនឹងលទ្ធផលឆ្នាំមុន។

លំហូរសាច់ប្រាក់សុទ្ធដែលប្រើប្រាស់លើការវិនិយោគនូវសាច់ប្រាក់មានចំនួន ១,៣ ប៊ីលានរៀល ក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ ដោយរាប់បញ្ចូលការសាងសង់លើបន្ទប់តាំងបង្ហាញថ្មី និងការទិញរថយន្តម៉ាកថ្មីសម្រាប់ប្រតិបត្តិការ និង ឧបករណ៍ប្រតិបត្តិការបន្ថែម។

## ខ. រចនាសម្ព័ន្ធប្រាក់ចំណូល

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនដែលមានលក្ខណៈបែបចម្រុះ ដែលបានតំណាងអោយយីហោលំដាប់ពិភព លោកមួយចំនួនរួមមាន Ford, Land Rover, Changan, After-Sales Mercedes-Benz, Fuso, John Deere, JCB និង Piaggio។ ផលចំណូលរបស់ក្រុមហ៊ុនទាំងអស់ ត្រូវបានបែងចែកជាពីរប្រភេទ៖

១. ការលក់ទំនិញ៖ ចំណូលទាក់ទងនឹងការលក់យានយន្ត និងឧបករណ៍ផ្សេងៗ។

២. ចំណូលពីសេវាកម្ម៖ ចំណូលទាក់ទងនឹងសេវាជួសជុល និងថែទាំយានយន្ត និងឧបករណ៍។

តារាងខាងក្រោមបង្ហាញពីចំណូលពីរប្រភេទសម្រាប់ ត្រីមាសទី៣ ឆ្នាំ២០២៤ និងរយៈពេលប្រៀបធៀបក្នុងកំឡុងពេលបី ឆ្នាំចុងក្រោយ។

| គិតជាពាន់រៀល | ត្រីមាសទី៣ ឆ្នាំ២០២៤ | ភាគរយ | ត្រីមាសទី៣ ឆ្នាំ២០២៣ | ភាគរយ | ត្រីមាសទី៣ ឆ្នាំ២០២២ | ភាគរយ |
|---|---|---|---|---|---|---|
| **ការលក់ទំនិញ** | ៣៣៦.៨៨២.៧០៨ | ៩៣,១% | ៣៤៦.៣៦៥.៥២៨ | ៩៤,៥% | ៧៧៣.១៤៧.៤៨០ | ៩៨,៤% |
| **ចំណូលនៃសេវាកម្ម** | ២៤.៨៣១.២០៣ | ៦,៩% | ២០.២៩២.១៨២ | ៥,៥% | ១២.៥៤៦.៤១១ | ១,៦% |
| **សរុប** | ៣៦១.៣១៣.៩១១ | ១០០,០% | ៣៦៦.៦៥៧.៧១០ | ១០០,០% | ៧៨៥.៦៩៣.៨៩១ | ១០០,០% |

## ផ្នែកទី៣.- របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករ

សូមយោងទៅលើឧបសម្ព័ន្ធស្តីពីព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នសម្រាប់បញ្ចប់ត្រីមាស គិតត្រឹម

ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤។

## ផ្នែកទី៤. ការពិភាក្សា និង ការវិភាគរបស់គណៈគ្រប់គ្រង

## ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ចំណូលសរុប មានចំនួន ៣៦១,៣ ប៊ីលានរៀល ធ្លាក់ចុះចំនួន -៥,៣ ប៊ីលានរៀល ឬ -១,៥% ភាគរយ នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ បើធៀបនឹងត្រីមាសដូចគ្នាក្នុងឆ្នាំ២០២៣។

### ២. ផ្នែកនៃចំណូល

ផ្នែកដែលនាំមុខគេគឺ ផ្នែករថយន្ត ហ្វដ (Ford) និង ផ្នែកបរិក្ខាកសិកម្ម (Agricultural Equipment)។ ចំណែកឯរថយន្ត Changan កំពុងកើនឡើងនៃការលក់ ខណៈពេលដែល រថយន្ត Land Rover បានបង្ហាញពីការធ្លាក់ចុះបន្តិច។

### ៣. ការវិភាគអំពីប្រាក់ចំណេញមុនបង់ពន្ធ (PBT)

| គិតជាពាន់រៀល | ត្រីមាសទី៣ ឆ្នាំ២០២៤ | ត្រីមាសទី៣ ឆ្នាំ២០២៣ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ចំណូលសរុប | ៣៦១.៣១៣.៩១១ | ៣៦៦.៦៥៧.៧១០ | (៥.៣៤៣.៧៩៩) | -១,៥% |
| ចំណេញដុល | ៥២.៧៤៩.៧៧៤ | ៥៨.៦៤៤.៨៧៧ | (៥.៨៩៥.១០៣) | -១០,១% |
| គម្លាតចំណេញដុល | ១៤,៦% | ១៦,០% | | |
| ចំណាយ | ៣១.១៤១.៤៦៨ | ៣៣.៩៣៧.៤៥៩ | (២.៧៩៥.៩៩១) | -៨,២% |
| ចំណាយហិរញ្ញវត្ថុ | ៥.៦៥៤.៤៩៧ | ៨.៧៥២.០៧២ | (៣.០៩៧.៥៧៥) | -៣៥,៤% |
| ប្រាក់ចំណេញមុនបង់ពន្ធ | ១៥.៩៥៣.៨០៩ | ១៥.៩៥៥.៣៤៦ | (១.៥៣៧) | ០,០% |
| គម្លាត | ៤,៤% | ៤,៤% | | |

### ៤. ការវិភាគអំពីប្រាក់ចំណេញក្រោយបង់ពន្ធ (PAT)

| គិតជាពាន់រៀល | ត្រីមាសទី៣ ឆ្នាំ២០២៤ | ត្រីមាសទី៣ ឆ្នាំ ២០២៣ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ១៥.៩៥៣.៨០៩ | ១៥.៩៥៥.៣៤៦ | (១.៥៣៧) | ០,០% |
| ចំណាយពន្ធ | ៣.៧៩៨.៥៤១ | ២.៧១១.៨២៧ | ១.០៨៦.៧១៤ | ៤០,១% |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | ១២.១៥៥.២៦៨ | ១៣.២៤៣.៥១៩ | (១.០៨៨.២៥១) | -៨,២% |
| គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ | ៣,៤% | ៣,៦% | | |

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ

### ១. ការវិភាគអំពីតម្រូវការ និង ការផ្គត់ផ្គង់

ជាទូទៅអតិថិជនរបស់ RMAC នៅក្នុងប្រទេសកម្ពុជាបានបង្ហាញពីចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការទិញផលិតផលសំខាន់ៗរបស់ RMAC ដែលមានដូច ជា Ford, Changan, John Deere និង Land Rover ។

បច្ចុប្បន្ន RMAC កំពុងតាមដានយ៉ាងដិតដល់នូវការនាំចូល និងប្រភពធនធាននៃផលិតផលសម្រាប់ផ្នែកនីមួយៗ ដើម្បីធ្វើការសម្រេចចិត្តសមស្របតាមលក្ខខណ្ឌនៃការបញ្ជាទិញផលិតផល។

### ២. ការវិភាគអំពីការប្រែប្រួលនូវតម្លៃវត្ថុធាតុដើម

មិនមានការប្រែប្រួលសំខាន់លើតម្លៃនៃវត្ថុធាតុដើមឡើយ។

### ៣. ការវិភាគអំពីពន្ធដារ

មិនមានការប្រែប្រួលលើលិខិតបទដ្ឋានគតិយុត្តិផ្នែកពន្ធដារក្នុងប្រទេសកម្ពុជាណាមួយ ដែលនាំអោយមានផលប៉ះពាល់សំខាន់ណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

### ៤. ការវិភាគអំពីទំនិញលើកលែង និងទំនិញពិសេស

មិនមានទំនិញលើកលែង និងទំនិញពិសេសក្នុងអំឡុងពេលនេះឡើយ។

## គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល

ចំណូលសម្រាប់ត្រីមាសទី៣ ឆ្នាំ២០២៤ ប្រៀបធៀបរយៈពេលដូចគ្នានាឆ្នាំ ២០២៣ ដែលត្រូវបានបង្ហាញក្នុងឯកសារនេះ និងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេប។

## ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ

ការប្រែប្រួលអត្រាប្តូរប្រាក់ មិនមានការប៉ះពាល់ចំបងណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ដោយហេតុថាអាជីវកម្មមួយចំនួនធំរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់រៀល/ប្រាក់ដុល្លារអាមេរិក ដោយភ្ជាប់ជាមួយនឹងការបញ្ជាទិញនូវផលិតផលនាំចូលតិចតួចប៉ុណ្ណោះដែលធ្វើឡើងជារូបិយបណ្ណបរទេស។ ក្រុមហ៊ុន មិនបានទទួលរងផលប៉ះពាល់ដោយតម្លៃទំនិញ ដោយសារក្រុមហ៊ុនមិនបានធ្វើការដោះដូរទំនិញឡើយ។ អត្រាការប្រាក់ មានការប្រែប្រួលបន្តិចបន្តួចតែប៉ុណ្ណោះក្នុងអំឡុងពេលនេះ។

## ង. ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ចំបងណាមួយនៃអតិផរណា ដែលបានប៉ះពាល់ដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

នាពេលថ្មីៗនេះ យើងមិនត្រូវទទួលបានការជូនដំណឹងអំពីគោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ ឬ រូបិយវត្ថុដែលអាចមានផលប៉ះពាល់ដល់អាជីវកម្មរបស់ RMAC តាមរបៀបណាមួយឡើយ។

## ឆ. ព្រឹត្តិការណ៍សំខាន់ផ្សេងៗ

មិនមានព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសនេះទេ។

ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ

កាលបរិច្ឆេទ៖ ២៩ កញ្ញា ២០២៤

បានឯកភាព និង អនុម័ត

ឈ្មោះ Kevin Whitcraft

តួនាទី៖ ប្រធានក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អ អិម អេ (ខេមបូឌា) ម.ក
R M A (CAMBODIA) PLC.
KINGDOM OF CAMBODIA

បានឯកភាព និង អនុម័ត

ឈ្មោះ ងន សាំង

តួនាទី៖ នាយកប្រតិបត្តិ

